# គណៈកម្មការប្រព័ន្ធផាត់ទាត់ និងទូទាត់សងប្រាក់

# របស់ធនាគារកណ្តាលអាស៊ាន

# ការចេញផ្សាយរួមគ្នា

## ការអនុម័តគោលការណ៍សម្រាប់តម្លាភាពផលិតផល និងការផ្សព្វផ្សាយសម្រាប់ការទូទាត់ពាណិជ្ជកម្មឆ្លងប្រទេស

គណៈកម្មការប្រព័ន្ធទូទាត់សងប្រាក់អាស៊ាន (WCPSS) បានចេញផ្សាយគោលការណ៍សម្រាប់តម្លាភាពផលិតផលនិងការផ្សព្វផ្សាយ ដើម្បីកែលម្អកម្រិតតម្លាភាពក្នុងការគិតកម្រៃ និងកម្រិតសេវា ដែលផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុនៅក្នុងតំបន់អាស៊ានសម្រាប់ការទូទាត់ពាណិជ្ជកម្មឆ្លងប្រទេស ។

គោលការណ៍នេះត្រូវបានរៀបចំឡើងដើម្បីធានាថា អតិថិជនទទួលបានព័ត៌មានច្បាស់លាស់ទាន់ពេលវេលា ងាយស្រួលក្នុងការចូលទៅប្រើប្រាស់ និងអាចធ្វើការប្រៀបធៀបព័ត៌មានសំខាន់ដើម្បីងាយស្រួលធ្វើការសម្រេចចិត្តក្នុងការទូទាត់ពាណិជ្ជកម្មឆ្លងប្រទេស ។ ប្រទេសម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ ជាក្រុមដំបូង ដែលនឹងចាប់ផ្តើមអនុវត្តន៍គោលការណ៍នេះនៅមុនខែកុម្ភៈ ឆ្នាំ២០១៥ ។ រីឯប្រទេសព្រុយណេ កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ភូមា និងវៀតណាម នឹងចាប់ផ្តើមអនុវត្តគោលការណ៍នេះនៅក្នុងឆ្នាំ២០១៥ ។

ការដាក់ឲ្យអនុវត្តគោលការណ៍នេះ គឺជាកត្តាជម្រុញមួយក្នុងកត្តាជម្រុញជាច្រើនសម្រាប់ធ្វើឲ្យប្រសើរឡើងកម្រិតប្រសិទ្ធភាពនៃការទូទាត់ពាណិជ្ជកម្មឆ្លងប្រទេសដើម្បីជម្រុញពាណិជ្ជកម្មរវាងសេដ្ឋកិច្ចអាស៊ាន ។ ដើម្បីបន្តពង្រឹងសមាហរណកម្មសេដ្ឋកិច្ចតំបន់អាស៊ាន គណៈកម្មការប្រព័ន្ធទូទាត់សងប្រាក់អាស៊ាន (WCPSS) នឹងសិក្សាស្វែងរកកត្តាជម្រុញជាគន្លឹះ ធ្វើឲ្យប្រសើរឡើងការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកសម្រាប់ការទូទាត់ពាណិជ្ជកម្មឆ្លងប្រទេស ។

គណៈកម្មការប្រព័ន្ធទូទាត់សងប្រាក់អាស៊ាន (WCPSS) មានគោលបំណងធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធផាត់ទាត់ និងទូទាត់សងប្រាក់សម្រាប់ប្រទេសជាសមាជិកអាស៊ានដែលបានត្រៀមខ្លួនជាស្រេច ដើម្បីទ្រទ្រង់សមាហរណកម្មហិរញ្ញវត្ថុក្នុងតំបន់នៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ។ កិច្ចសហប្រតិបត្តិការ និងការគាំទ្ររវាងប្រទេសជាសមាជិកអាស៊ានដើម្បីធ្វើឲ្យប្រសើរឡើងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ក្នុងស្រុក គឺត្រូវតែមានជាចាំបាច់ដើម្បី

សម្របសម្រួលដល់ការបង្កើតសេវាទូទាត់សងប្រាក់ឆ្លងប្រទេសដែលបំពេញមុខងារដោយរលូន មានប្រសិទ្ធភាព និងសុវត្ថិភាព ។

## អំពីគណៈកម្មការប្រព័ន្ធផាត់ទាត់ និងទូទាត់សងប្រាក់របស់ធនាគារកណ្តាលអាស៊ាន

ធនាគារកណ្តាលប្រទេសអាស៊ានបានបង្កើត គណៈកម្មការប្រព័ន្ធទូទាត់សងប្រាក់អាស៊ាន នៅក្នុងខែមេសា ឆ្នាំ២០១០ ដើម្បីធ្វើឲ្យប្រសើរឡើងប្រព័ន្ធផាត់ទាត់ និងទូទាត់សងប្រាក់របស់បណ្តាប្រទេសអាស៊ាន ដើម្បីគាំទ្រដល់សមាហរណកម្មហិរញ្ញវត្ថុ រវាងប្រទេសនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ។ ប្រទេសដែលជាសមាជិកទាំងដប់នៅក្នុងគណៈកម្មការប្រព័ន្ធផាត់ទាត់និងទូទាត់សងប្រាក់អាស៊ាន មានប្រទេសម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ ព្រុយណេ កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ភូមា និងវៀតណាម ។ គណៈកម្មការប្រព័ន្ធផាត់ទាត់និងទូទាត់សងប្រាក់អាស៊ាននឹងធ្វើការសិក្សានិងផ្តល់ជូនអនុសាសន៍ជាគោលនយោបាយដើម្បីជម្រុញប្រព័ន្ធផាត់ទាត់ និងទូទាត់សងប្រាក់ក្នុងតំបន់រួមគ្នាតែមួយប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពក្នុងវិស័យសំខាន់ចំនួនប្រាំដែលរួមមានការទូទាត់ពាណិជ្ជកម្ម ការផ្ទេរប្រាក់ ការទូទាត់សងប្រាក់តម្លៃរាយ ទីផ្សារទុន និងការធ្វើឲ្យមានស្តង់ដាររួម ។ ប្រការនេះ អាចអនុញ្ញាតឲ្យក្រុមហ៊ុន និងឯកត្តបុគ្គលធ្វើការទូទាត់ ឬទទួលការទូទាត់សងប្រាក់ជាអេឡិចត្រូនិកឲ្យកាន់តែមានភាពងាយស្រួល ។